ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៤៤៤៩០ ប្រក.

# ប្រកាស
# ស្តីពី
# ការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា សម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២ .-**

និមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានរូបភាព និងខ្លឹមសារដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងមូល និងមានផ្ទៃខាងក្នុងចំនួនពីរពណ៌ ដែលផ្ទៃកណ្តាលមានពណ៌ស និងព័ទ្ធជុំវិញដោយផ្ទៃពណ៌ខៀវ។ ការខណ្ឌចែករវាងផ្ទៃទាំងពីរ គឺមានរង្វង់ពីរជាន់ ស និងខៀវ
- អក្សរ **"ការិយាល័យប្រជាពលរដ្ឋ"** មានពណ៌សរាងកោងកន្លះរង្វង់ចំផ្ទៃពណ៌ខៀវផ្នែកខាងលើដែលមានន័យថាជាយន្តការបង្កើតឡើងដោយរាជរដ្ឋាភិបាលកំពុងអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- **រូបផ្កាច័ន្ទពណ៌ស៖** នៅសងខាងខណ្ឌចែកកន្លះរង្វង់ផ្ទៃពណ៌ខៀវតំណាងឱ្យនិមិត្តរូបនារីខ្មែរ គឺនាងនាគ (ក្នុងរឿងព្រេងព្រះថោងនាងនាគ) និងគោលការណ៍នៃការបញ្ជាបយេនឌ័រក្នុងការផ្តល់សេវាសាធារណៈនាសម័យកាលទំនើបបច្ចុប្បន្ន
- អក្សរ **"OMBUDSMAN OFFICE"** មានពណ៌សរាងកោងកន្លះរង្វង់ចំផ្ទៃពណ៌ខៀវផ្នែកខាងក្រោម៖ មានន័យថាជាកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាយន្តការកំពុងត្រូវបានអនុវត្តលើសកលលោកទាំងវិស័យសាធារណៈ និងវិស័យឯកជន
- **រូបអគារមានក្បាច់រចនា និងពណ៌ដូចនឹងអគារសាលាស្រុក ដាក់ចំកណ្តាលផ្នែកខាងលើនៃផ្ទៃពណ៌ស៖** តំណាងឱ្យអគាររដ្ឋបាលនៅថ្នាក់ក្រោមជាតិដែលជាទីកន្លែងបំពេញការងាររបស់មន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- **រូបជើងពានពណ៌មាសទ្រសៀវភៅពណ៌ខៀវនៅក្រោមរូបអគារ៖** មានន័យថាការិយាល័យប្រជាពលរដ្ឋមានតួនាទីទទួល សម្រុះសម្រួលដោះស្រាយបណ្តឹងដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធី
- អក្សរ **"អព្យាក្រឹត តម្លាភាព យុត្តិធម៌"** មានពណ៌ខៀវ៖ សរសេររាងកោងស្ថិតនៅកជើងពានមានន័យថាការិយាល័យប្រជាពលរដ្ឋអនុវត្តនីតិវិធីនៃការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងដោយប្រកាន់ខ្ជាប់គោលការណ៍ **អព្យាក្រឹត តម្លាភាព យុត្តិធម៌**។

**ប្រការ៣ .-**

និមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រើប្រាស់ជាផ្លូវការដូចខាងក្រោម៖

- ដាក់តាំងនៅលើអគារការិយាល័យបំពេញការងាររបស់បុគ្គលិកការិយាល័យប្រជាពលរដ្ឋ
- ដាក់នៅលើក្បាលលិខិតទំនាក់ទំនងការងាររបស់ការិយាល័យប្រជាពលរដ្ឋ
- បោះពុម្ពលើខិត្តប័ណ្ណផ្សព្វផ្សាយនានារបស់ការិយាល័យប្រជាពលរដ្ឋ
- បំពាក់លើឯកសណ្ឋានបំពេញការងាររបស់បុគ្គលិកការិយាល័យប្រជាពលរដ្ឋ
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ២ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ......៤៤៩០......ប្រក

ចុះថ្ងៃ......សុក្រ ៤កើត......ខែ......ស្រាពណ៍......ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី......១៨......ខែ......សីហា......ឆ្នាំ២០២៣

ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ